# ការប្រកួតប្រជែងស្នៃម By Smart

## ការកែច្នៃក្រដាសដែលប្រើប្រាស់រួចទៅជាក្រដាសថ្មីដែលអាចប្រើម្តងទៀត


បេក្ខជនទី១៖ ហុក ធិរាជធីត្តា

បេក្ខជនទី២៖ សារិន សូលីហ្សា

*ឈ្មោះសាលា ហ៉ើរ៉ូដស៍ អន្តរជាតិ* (Harrods International Academy)

*មកពីក្រុងភ្នំពេញ*


**ប្រភេទប្រធានវិញ្ញាសា:** វិទ្យាសាស្ត្របរិស្ថាន

**ប្រភេទក្រុមប្រកួត:** ក្រុមយុវជនវ័យជំទន់៖ ថ្នាក់ទី៧ (Junior)

### សេចក្តីសង្ខេបអំពីគម្រោង

ក្រុមនាងខ្ញុំបានជ្រើសរើសយកប្រធានបទ "ការកែច្នៃក្រដាសដែលប្រើរួចទៅជាក្រដាសថ្មីមួយដែលអាចប្រើម្តងទៀតបាន"។ យើងសង្កេតឃើញថាមនុស្សមួយចំនួនបានប្រើក្រដាសរាមដោយគ្មានការសន្សំសំចៃដោយសរសេរមិនទាន់ពេញផងក៏បោះវាចោលបាត់ទៅនិងអ្នកខ្លះទៀតយកវាទៅបត់ ឬតុបតែងអ្វីមួយរួចក៏យកវាទៅបោះចោលទៅ។ ដោយចាប់អារម្មណ៍ទៅលើការខ្ជះខ្ជាយនៃការប្រើប្រាស់ក្រដាសដូចនេះហើយបានជាក្រុមយើងខ្ញុំសម្រេចចិត្តយកប្រធានបទនេះឡើង។ ក្រដាសដែល យើងបោះចោលក្រោយពីប្រើប្រាស់ហើយមានច្រើនប្រភេទដូចជា ក្រដាសរ៉ាមដែលយើងបានប្រើប្រាស់រួច ក្រដាសកាសែត ក្រដាសខ្ចប់ម្ហូបអាហារដូចជាប៊ីហ្គឺ មាន់បំពង ភីហ្សា ក្រដាសឡាំង ឬកេសផ្សេង...។ ការកែច្នៃឡើងវិញនេះខ្ញុំនឹងធ្វើពិសោធន៍ដោយពាក់ព័ន្ធតែនឹងក្រដាសរ៉ាមដែលយើងប្រើប្រាស់រួចដោយធ្វើការកែច្នៃពីររបៀបគឺ របៀបទី១: ការកែច្នៃក្រដាសរាមដោយប្រើទឹកធម្មតា និងរបៀបទី២: ការកែច្នៃក្រដាសដោយប្រើទឹកក្តៅ។ ជាលទ្ធផលយើងអាចយកក្រដាសដែលកែច្នៃរួចទាំងពីរប្រភេទនេះទៅប្រើប្រាស់ដូចជា ធ្វើក្រដាសសម្រាប់កត់ត្រាចំណាំក្នុងសៀវភៅ (bookmark) ក្រដាសជូនពរ (postcard) ក្រដាសសម្រាប់តុបតែងលំអផ្សេងៗ ក្រដាសសម្រាប់គូរគំនូរ...។


Organised by

Supported by

Sponsored by